- ថែរក្សាបញ្ជីផលិតករ ឬអ្នកកែច្នៃ និងប្រតិបត្តិករ ដែលទទួលស្គាល់ដោយភ្នាក់ងារ ឬស្ថាប័នត្រួតពិនិត្យពីខាងក្រៅ និងផ្តល់ព័ត៌មានដល់សមាជិក ភ្នាក់ងារ ឬស្ថាប័នត្រួតពិនិត្យ និងនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ទៅតាមការស្នើសុំ
- ចាត់វិធានការទៅតាមផ្លូវច្បាប់ដើម្បីការពារទប់ទល់នឹងការក្លែងបន្លំផលិតផល
- បេសកកម្មផ្សេងៗទៀតដែលនាំឱ្យសមាគមឈានទៅសម្រេចគោលបំណងរបស់ខ្លួន ។

## ជំពូកទី ២
## ការកំណត់ឈ្មោះ ទីស្នាក់ការ សញ្ញាសម្គាល់ និងត្រា

### ប្រការ ២.- អំពីការកំណត់ឈ្មោះ

សមាគមមានឈ្មោះជាភាសាខ្មែរថា **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប**សហៅកាត់ថា **"ស.ផ.អ.ក.ក"** និងមានឈ្មោះជាភាសាអង់គ្លេសថា Association of Geographical Indication Kampot-Kep Salt ហៅកាត់ថា "AGIKS"។

### ប្រការ ៣.- អំពីទីស្នាក់ការ

**សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** មានទីស្នាក់ការណ្តាលតាំងនៅខេត្តកំពត។ សមាគមអាចបង្កើតឱ្យមានទីស្នាក់ការ ឬផ្លាស់ប្តូរទៅតាមតម្រូវការចាំបាច់របស់សមាគម។

### ប្រការ ៤.- អំពីអត្តសញ្ញាណ

**សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** គឺជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃ មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារៈ ហិរញ្ញវត្ថុធនធាន មនុស្សគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ គឺជាសមាគមបម្រើឱ្យសមាជិកភាពប៉ុណ្ណោះ។

### ប្រការ ៥.- អំពីសញ្ញាសម្គាល់ និងត្រា

- **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** មានសញ្ញាសម្គាល់ដូចបានកំណត់នៅក្នុងឧបសម្ព័ន្ធ ដែលភ្ជាប់មកជាមួយលក្ខន្តិកៈនេះ។
- ត្រារបស់ **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** មានរាងមូលពីរជាន់មានទំហំ ៣៤ម.ម ដែលជាន់ទី១ផ្នែក ខាងលើមានឈ្មោះសមាគមជាភាសាខ្មែរ ផ្នែកខាងក្រោមមានឈ្មោះសមាគមជាភាសាអង់គ្លេស និងនៅចំកណ្តាលរង្វង់មូលទី២ មានរូបសញ្ញាសម្គាល់សមាគម ដោយកំណត់ប្រើនូវប្រភេទទឹកត្រាពណ៌ខៀវ។

## ជំពូកទី ៣
## សមាជិកភាព ការបាត់បង់សមាជិកភាព និងបុគ្គលិកភាព

**ប្រការ ៦.- អំពីសមាជិកភាព**

បុគ្គលដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ ផលិតករ សិប្បករ អាជីវករ ប្រតិបត្តិករ អ្នកពាក់ព័ន្ធ និងគាំទ្រ **"អំបិលកំពតកែប"** មានសិទ្ធិសុំចូលជាសមាជិករបស់សមាគម។ រាល់សមាជិករបស់សមាគមទាំងអស់ ត្រូវគោរព និងអនុវត្តទៅតាមច្បាប់នានា លិខិតបទដ្ឋានគតិយុត្តនានានៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង សៀវភៅបន្ទុក "អំបិលកំពតកែប" និងរាល់សេចក្តីសម្រេចរបស់សមាគម។

**ប្រការ ៧.- អំពីសមាជិករបស់សមាគម**

សមាជិករបស់ **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** រួមមាន៖

១- **សមាជិកស្ថាបនិក៖** គឺជាអ្នកដែលបានផ្តួចផ្តើមបង្កើតសមាគមនេះឡើង

២- **សមាជិកកិត្តិយស៖** គឺជាអ្នកដែលបានចូលរួមផ្តល់ជាគំនិតយោបល់ជួយជ្រោមជ្រែងដល់សមាគមនេះ ដើម្បីបានបង្កើត និងដំណើរការដោយមិនគិតអំពីផលប្រយោជន៍ផ្ទាល់ខ្លួន

៣- **សមាជិកសកម្ម៖** គឺជាអ្នកចូលរួមអនុវត្តក្នុងសកម្មភាពរបស់សមាគម ក្នុងនោះមានដូចជាការពិភាក្សាផ្តល់នូវបទពិសោធន៍រាល់កិច្ចការ និងសំណូមពរផ្សេងៗរបស់សមាគម

៤- **សមាជិកគាំទ្រ៖** គឺជាអ្នកដែលផ្តល់នូវប្រភពធនធាន មានដូចជា សម្ភារៈ ថវិកា និងស្មារតីនៃការគាំទ្រឱ្យសមាគមមានដំណើរការស្របតាមគោលបំណងរបស់ខ្លួន។

**ប្រការ ៨.- អំពីការជ្រើសរើសបុគ្គលិក**

**សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** អាចជ្រើសរើសបុគ្គលិកឱ្យចូលបម្រើការងារទៅតាមការចាំបាច់របស់សមាគម នឹងត្រូវអនុវត្តតាមរយៈការប្រឡង ឬការធ្វើតេស្ត និងត្រូវចុះកិច្ចសន្យាការងារដោយអនុលោមទៅ តាមច្បាប់ស្តីពី ការងារ របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៩.- អំពីតួនាទី ភារកិច្ចរបស់សមាជិក និងបុគ្គលិក**

គ្រប់សមាជិក និងបុគ្គលិករបស់សមាគម ត្រូវបំពេញការងារតាមតួនាទី និងភារកិច្ចរបស់ខ្លួន ទៅតាមការកំណត់ដូចមានចែងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចនានារបស់សមាគម។

គ្រប់សមាជិកនិងបុគ្គលិករបស់សមាគម មិនត្រូវបានអនុញ្ញាតឱ្យយកឈ្មោះរបស់សមាគមទៅបម្រើនៅក្នុងផលប្រយោជន៍បុគ្គល ឬបម្រើឱ្យផលប្រយោជន៍គណបក្សនយោបាយណាមួយឡើយ។

**អំពីសិទ្ធិរបស់សមាជិក**

សមាជិកស្ថាបនិក និងសមាជិកសកម្ម មានសិទ្ធិដូចគ្នា រួមមាន៖

- ចូលរួមមហាសន្និបាតរបស់សមាគម
- ឈរឈ្មោះឱ្យគេបោះឆ្នោតសម្រាប់សមាជិកគណៈកម្មការប្រតិបត្តិ ឬក្រុមប្រឹក្សា

- បោះឆ្នោតធ្វើសេចក្ដីសម្រេចិត្តក្នុងសមាគម
- ផ្ដល់យោបល់ និងបញ្ចេញមតិលើដំណើរការ និងការគ្រប់គ្រងរបស់សមាគម។

សមាជិកកិត្តិយស និងសមាជិកគាំទ្រ មានសិទ្ធិ៖

- ចូលរួមមហាសន្និបាតរបស់សមាគម តែមិនមានសិទ្ធិក្នុងការចូលរួមបោះឆ្នោត
- ផ្ដល់យោបល់ និងបញ្ចេញមតិលើដំណើរការ និងការគ្រប់គ្រងរបស់សមាគម។

## ប្រការ១០.- អំពីការបាត់បង់សមាជិកភាព និងបុគ្គលិកភាព

ចំពោះការបាត់បង់សមាជិកភាព និងបុគ្គលិកភាពរបស់សមាគម ត្រូវបានកំណត់ក្នុងលក្ខខណ្ឌ ដូចខាងក្រោម៖

**ចំពោះសមាជិកភាព៖**

- ទទួលមរណភាព
- បានដាក់ពាក្យសុំលាឈប់ដោយផ្ទាល់ជាលាយលក្ខណ៍អក្សរ ដោយត្រូវដាក់ជូនទៅគណៈកម្មការប្រតិបត្តិឱ្យបាន១៥ (ដប់ប្រាំ)ថ្ងៃ មុននឹងលាឈប់
- មិនបានបង់ថវិកាសមាជិកភាព ថវិកាទ្រទ្រង់សមាគម និងថ្លៃសេវាកម្មផ្សេងៗដែល **សមាគមអ្នកផលិតអំបិលកំពត កែប** ធ្វើសម្រាប់សមាជិក ទៅតាមបទបញ្ជាផ្ទៃក្នុង និងសេចក្ដីសម្រេចរបស់មហាសន្និបាត។
- មានជាប់ពិរុទ្ធក្នុងបទល្មើសមជ្ឈិម ឬបទល្មើសព្រហ្មទណ្ឌណាមួយ ដែលមានសាលក្រម ឬសាលដីកាស្ថាពរ ដោយតុលាការក្នុងព្រះរាជាណាចក្រកម្ពុជា
- មានជំងឺវិបល្លាសស្មារតី ឬវិកលចរិត ដែលមានលិខិតបញ្ជាក់ចេញដោយមន្ទីរពេទ្យស្របច្បាប់ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ចំពោះបុគ្គលិក**

- ទទួលមរណភាព
- ចប់កិច្ចសន្យាការងារ
- ដាក់ពាក្យលាឈប់ពីការងារ
- មានជាប់ពិរុទ្ធក្នុងបទល្មើសមជ្ឈិម ឬបទល្មើសព្រហ្មទណ្ឌណាមួយ ដែលមានសាលក្រម ឬសាលដីកាស្ថាពរ ដោយតុលាការក្នុងព្រះរាជាណាចក្រកម្ពុជា
- មានជំងឺវិបល្លាសស្មារតី ឬវិកលចរិត ដែលមានលិខិតបញ្ជាក់ចេញដោយមន្ទីរពេទ្យស្របច្បាប់ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ១១.- អំពីការបញ្ឈប់ និងការជ្រើសរើស

ក្នុងករណីការបញ្ឈប់សមាជិកគណៈកម្មការប្រតិបត្តិណាមួយនោះ គណៈកម្មការប្រតិបត្តិត្រូវប្រជុំគ្នាដើម្បីជ្រើសរើសអ្នកថ្មីមកជំនួសជាបណ្ដោះអាសន្នសម្រាប់រយៈពេលយ៉ាងយូរ ៦ខែ និងបន្ទាប់មកស្នើសុំមហាសន្និបាតដើម្បីសម្រេច។

ក្នុងករណីការបញ្ឈប់សមាជិកបុគ្គលិកណាមួយនោះ គណៈកម្មការប្រតិបត្តិត្រូវប្រជុំគ្នាដើម្បីជ្រើសរើសអ្នកថ្មីមកជំនួស។

## ជំពូកទី ៤
## រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច

**ប្រការ១២.- អំពីរចនាសម្ព័ន្ធ**

**សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** មានរចនាសម្ព័ន្ធគ្រប់គ្រង ដូចខាងក្រោម៖

- **មហាសន្និបាត៖** គឺជាស្ថាប័នដឹកនាំកំពូលរបស់សមាគម មហាសន្និបាតរួមមាន៖ មហាសន្និបាតសាមញ្ញ និងមហាសន្និបាតវិសាមញ្ញ
- ទីប្រឹក្សា
- គណៈកម្មការប្រតិបត្តិ
- សវនកម្មផ្ទៃក្នុង។

**ប្រការ១៣.- អំពីមហាសន្និបាតសាមញ្ញ**

**មហាសន្និបាតសាមញ្ញ** ត្រូវរៀបចំឡើងរៀងរាល់មួយឆ្នាំម្តង ដោយមានការចូលរួមពីសមាជិកទាំងអស់របស់សមាគម តាមការអញ្ជើញរបស់ប្រធានសមាគម យ៉ាងហោចណាស់ ១៤ថ្ងៃ មុនមហាសន្និបាត។ សមាជិកកិត្តិយសមានសិទ្ធិចូលរួមក្នុងអង្គមហាសន្និបាតបាន ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោត ឬឈរឈ្មោះឱ្យគេបោះឆ្នោតនោះទេ។ រីឯនីតិវិធី របៀបវារៈ ទីកន្លែង និងពេលវេលាជាភារកិច្ចរបស់ រដ្ឋបាល។

**មហាសន្និបាតសាមញ្ញមានភារកិច្ច**

- បោះឆ្នោតជ្រើសរើស សមាជិកគណៈកម្មការប្រតិបត្តិ នៅពេលចប់អាណត្តិ
- ពិនិត្យ និងវាយតម្លៃលើរបាយការណ៍ស្តីពី សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុដែលបានអនុវត្តកន្លងមក
- ពិនិត្យ និងអនុម័តលើទិសដៅ គោលបំណង សកម្មភាព និងថវិកាសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់
- ពិនិត្យ និងអនុម័តលើការធ្វើវិសោធនកម្មលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង សៀវភៅបន្ទុក "**អំបិលកំពតកែប**" ឬលក្ខខណ្ឌការងារ
- ពិនិត្យ និងដោះស្រាយការងារផ្សេងៗទៀត ដែលស្នើឡើងដោយគណៈកម្មការប្រតិបត្តិ។

**ប្រការ១៤.- អំពីមហាសន្និបាតវិសាមញ្ញ**

ក្នុងករណីចាំបាច់ ឬពិសេស សមាគមអាចរៀបចំមហាសន្និបាតវិសាមញ្ញបាន ដោយមិនកំណត់ពេលវេលាតាមការអញ្ជើញរបស់ប្រធានសមាគម ឬតាមសំណើសុំ ២/៣ (ពីរភាគបី) នៃចំនួនសមាជិកគណៈកម្មការប្រតិបត្តិរបស់សមាគម ឬតាមសំណើរ ១/៣ (មួយភាគបី) នៃសមាជិកសកម្មរបស់សមាគម។

**មហាសន្និបាតវិសាមញ្ញមានភារកិច្ច**

- ពិនិត្យ ពិភាក្សាកែប្រែ និងអនុម័តលក្ខន្តិកៈ ឬសៀវភៅបន្ទុក "**អំបិលកំពតកែប**" ក្នុងករណីចាំបាច់
- ពិនិត្យ សម្រេចលើការផ្លាស់ប្តូរប្រធានសមាគម
- ពិនិត្យ និងអនុម័តលើការរំលាយសមាគម និងការបែងចែកទ្រព្យសម្បត្តិរបស់សមាគម
- ពិនិត្យ និងដោះស្រាយការងារផ្សេងៗទៀត ដែលចាំបាច់នៅក្នុងសមាគម។

**ប្រការ១៥.- អំពីលក្ខណ:គតិយុត្ត**

រាល់សេចក្តីសម្រេចរបស់អង្គមហាសន្និបាតទាំង ២(ពីរ)ប្រភេទ មានតម្លៃគតិយុត្តបាន លុះត្រាតែមានការអនុម័តដោយសំឡេងគាំទ្រភាគច្រើន ៥០%+១ នៃសមាជិកសកម្មដែលចូលរួម និងលើកូរ៉ុមចូលរួមក្នុងមហាសន្និបាតយ៉ាងហោចណាស់ ២/៣ (ពីរភាគបី) នៃសមាជិកសកម្ម។

ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានអង្គមហាសន្និបាតមានឧត្តមានុភាព។ ប្រធានអង្គមហាសន្និបាត អាចជាប្រធានសមាគម ឬបុគ្គលដែលមានឯករាជ្យភាពតាមការជ្រើសរើសរបស់អង្គមហាសន្និបាត។

សមាជិកសកម្មត្រូវចូលរួមដោយផ្ទាល់ក្នុងមហាសន្និបាតដើម្បីបោះឆ្នោតធ្វើសេចក្តីសម្រេចចិត្តនានា ដោយមិនមានអ្នកជំនួសបាន។

**ប្រការ១៦.- អំពីក្រុមប្រឹក្សា**

ក្រុមប្រឹក្សាមានសមាជិកយ៉ាងតិច ៣រូប និងមានអាណត្តិ ០៥(ប្រាំ) ឆ្នាំ។ ពេលបញ្ចប់អាណត្តិនីមួយៗ សមាជិកក្រុមប្រឹក្សាមានសិទ្ធិឈរឈ្មោះសាជាថ្មី ដើម្បីមហាសន្និបាតបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត។ ក្រុមប្រឹក្សាមានតួនាទីត្រឹមតែជាអ្នកផ្តល់យោបល់ដល់សមាគម ដោយមិនមានសិទ្ធិសម្រេចអ្វីទាំងអស់។

លក្ខណ:វិនិច្ឆ័យរបស់ក្រុមប្រឹក្សា នឹងមានចែងលម្អិតនៅក្នុងបទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចផ្សេងៗរបស់សមាគម។

**ប្រការ១៧.- អំពីគណ:កម្មការប្រតិបត្តិ**

គណៈកម្មការប្រតិបត្តិ មានសមាជិកយ៉ាងតិច ៧(ប្រាំពីរ)រូប និងមានអាណត្តិ ៥(ប្រាំ)ឆ្នាំ។ នៅពេលបញ្ចប់អាណត្តិនីមួយៗ សមាជិកគណៈកម្មការប្រតិបត្តិចាស់ មានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតជាថ្មីទៀតបាន។

ចំនួនជាក់លាក់នៃគណៈកម្មការប្រតិបត្តិ នឹងស្នើឡើងដោយគណៈកម្មការប្រតិបត្តិទៅមហាសន្និបាតដើម្បីសម្រេច។

**ប្រការ១៨.- អំពីសមាជិកគណ:កម្មការប្រតិបត្តិ**

សមាជិកគណៈកម្មការប្រតិបត្តិ ជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតដោយសំឡេងគាំទ្រ ៥០%+១ នៃសមាជិកសកម្មទាំងអស់ របស់សមាគមដែលបានចូលរួមមហាសន្និបាត។ គណៈកម្មការប្រតិបត្តិមានសមាសភាព ដូចខាងក្រោម៖

- ប្រធាន ១ រូប
- អនុប្រធាន ២ រូប
- រដ្ឋបាល ១ រូប
- ហេរញ្ញិក ១ រូប
- ប្រធានកម្មវិធី ១ រូប
- សមាជិក ១ រូប

នីតិវិធីនៃការបោះឆ្នោតជ្រើសតាំងគណៈកម្មការប្រតិបត្តិ នឹងមានចែងលម្អិតនៅក្នុងបទបញ្ជាផ្ទៃក្នុងសមាគម។

**ប្រការ១៩.- អំពីប្រធានគណៈកម្មការប្រតិបត្តិ**

ប្រធានគណៈកម្មការប្រតិបត្តិ គឺជាប្រធានសមាគម និងជាតំណាងស្របច្បាប់របស់សមាគម ដែលមានតួនាទីជាអ្នកទទួលបន្ទុកការងាររួម និងទទួលខុសត្រូវនូវគ្រប់សកម្មភាពរបស់សមាគម ដែលរួមមាន៖

- គ្រប់គ្រងការងារទូទៅ និងទទួលខុសត្រូវរួមរាល់កិច្ចការរបស់សមាគម
- ចុះហត្ថលេខាលើឯកសារ និងកិច្ចសន្យានានា
- កោះអញ្ជើញ និងរៀបចំអង្គប្រជុំ និងមហាសន្និបាត
- ដឹកនាំរៀបចំយុទ្ធសាស្ត្រ និងផ្សព្វផ្សាយផែនការរបស់សមាគម
- តំណាងឱ្យ **ស.ផ.អ.ក.ក** ក្នុងការទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅ ដែលរួមមានទំនាក់ទំនងការងារ និងការចូលរួមប្រជុំផ្សេងៗ
- ជួយពង្រឹងសម្ពភាពសមាជិក
- ផ្ទេរសិទ្ធិទៅឱ្យអនុប្រធាន និងសមាជិកគណៈកម្មការប្រតិបត្តិដទៃទៀត ទៅតាមលំដាប់លំដោយក្នុងករណីអវត្តមាន
- ទំនាក់ទំនង និងស្វែងរកភ្នាក់ងារ ឬស្ថាប័នត្រួតពិនិត្យពីខាងក្រៅ ។

**ប្រការ២០.- អំពីអនុប្រធាន**

**អនុប្រធានគណៈកម្មការប្រតិបត្តិ**

អនុប្រធានសមាគម មានតួនាទី និងភារកិច្ច

- ធ្វើការទំនាក់ទំនងជាមួយសហគមន៍ជាតិ អង្គការជាតិ និងអង្គការអន្តរជាតិទាំងក្នុង និងក្រៅប្រទេស
- មានសិទ្ធិស្នើ និងផ្តល់យោបល់ជ្រើសរើសប្រធានផ្នែកដើម្បីធ្វើការផ្លាស់ប្តូរប្រធានផ្នែកផ្សេងៗតាមសេចក្តីត្រូវការចាំបាច់ក្នុងសមាគម
- ជាជំនួយការរបស់ប្រធាន លើការងារគ្រប់គ្រងដឹកនាំសមាគម
- ជាតំណាងរបស់ប្រធានករណីប្រធានអវត្តមាន ដែលបានផ្ទេរសិទ្ធិជាប្រធានស្តីទី និងធ្វើជារបាយការណ៍ឱ្យប្រធាននៅពេលប្រធានត្រឡប់មកវិញ។
- ក្រៅពីនេះ តួនាទីនិងភារកិច្ចលម្អិតរបស់អនុប្រធានទាំង ២(ពីរ) នឹងមានចែងលម្អិតបន្ថែមទៀតនៅក្នុងបទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចផ្សេងៗទៀតរបស់សមាគម។

**ប្រការ២១.- អំពីរដ្ឋបាល/ហេរញ្ញិក**

**ក- អំពីរដ្ឋបាល**

មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងការងាររដ្ឋបាល ទ្រព្យសម្បត្តិ សារពើភណ្ឌ
- រៀបចំលិខិតបទដ្ឋាន និងរក្សាតម្កល់ទុកឯកសារ
- គ្រប់គ្រងការងារបុគ្គលិក
- ធ្វើកំណត់ហេតុអង្គប្រជុំនានា និងមហាសន្និបាត
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ

ខ- អំពីហេរញ្ញិក

- គ្រប់គ្រង និងត្រួតពិនិត្យរាល់ចំណូល និងចំណាយរបស់សមាគម
- ធ្វើគម្រោងថវិកាប្រចាំឆ្នាំ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុជូនប្រធានសមាគម ដើម្បីដាក់ជូនទៅគណៈកម្មការប្រតិបត្តិពិនិត្យ និងសម្រេចដោយមហាសន្និបាត
- សហការជាមួយសវនករពីខាងក្រៅ នៅពេលមានបេសកកម្មសវនកម្មហិរញ្ញវត្ថុរបស់សមាគម

**ប្រការ២២.- ប្រធានកម្មវិធីមានតួនាទី និងភារកិច្ច (កម្មវិធីត្រួតពិនិត្យ)**

- រៀបចំកម្មវិធីនានា (ត្រួតពិនិត្យអំបិលកំពតកែប) ជូនប្រធានសមាគមពិនិត្យ និងសម្រេចដោយគណៈកម្មការប្រតិបត្តិ
- រៀបចំផែនការត្រួតពិនិត្យផលិតផលអំបិលកំពតកែប សម្រាប់ដាក់ជូនគណៈកម្មការប្រតិបត្តិ
- រៀបចំ និងដំណើរការគណៈកម្មការ ឬក្រុមត្រួតពិនិត្យផ្ទៃក្នុង
- សហការជាមួយភ្នាក់ងារត្រួតពិនិត្យពីខាងក្រៅ
- រៀបចំបទដ្ឋាន (នីតិវិធី បញ្ជី ឧបករណ៍ ។ល។) ត្រួតពិនិត្យទៅតាមសៀវភៅបន្ទុក
- សហការជាមួយអនុប្រធានទាំង ២(ពីរ) ដើម្បីត្រួតពិនិត្យទិន្នន័យផលិតកម្ម និងលក់ដូរ។

**ប្រការ២៣.- អំពីក្រុមសវនកម្មផ្ទៃក្នុង**

**សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** មានក្រុមសវនកម្មផ្ទៃក្នុង ដែលមានសវនករយ៉ាងតិចចំនួន ៣រូប ជ្រើសរើសដោយមហាសន្និបាត។

**តួនាទី និងភារកិច្ចរបស់ក្រុមសវនកម្មផ្ទៃក្នុង**

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពការងាររបស់គណៈកម្មការប្រតិបត្តិ និងរៀបចំរបាយការណ៍បញ្ជូនទៅឱ្យគណៈកម្មការប្រតិបត្តិ និងមហាសន្និបាត
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ (របាយការណ៍ការចំណូល និងចំណាយរបស់សមាគម)
- ផ្តល់អនុសាសន៍ និងតម្រង់ទិសគណៈកម្មការប្រតិបត្តិលើនីតិវិធីការងារ ដើម្បីឱ្យប្រតិបត្តិទៅតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង គោលនយោបាយ ព្រមទាំងការសម្រេចនានា ដែលបានអនុម័តដោយមហាសន្និបាតរបស់សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប
- សហការជាមួយសវនកម្មខាងក្រៅ ។

**ប្រការ២៤.- អំពីកិច្ចប្រជុំគណៈកម្មការប្រតិបត្តិ**

គណៈកម្មការប្រតិបត្តិ ត្រូវជួបប្រជុំគ្នា ១(មួយ)ដង ក្នុងមួយខែ តាមការអញ្ជើញរបស់ប្រធានសមាគម និងអាចប្រជុំជាវិសាមញ្ញបានតាមការស្នើសុំរបស់ប្រធានសមាគម ឬ២/៣(ពីរភាគបី) នៃសមាជិកគណៈកម្មការប្រតិបត្តិ។

**ប្រការ២៥.- អំពីលក្ខណៈគតិយុត្ត**

រាល់សេចក្តីសម្រេចរបស់អង្គប្រជុំគណៈកម្មការប្រតិបត្តិទាំង (២ពីរ)ប្រភេទ មានតម្លៃគតិយុត្តបាន លុះត្រាតែមានការអនុម័តដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត ៥០%+១ លើកូរ៉ុមចូលរួមក្នុងអង្គប្រជុំយ៉ាងហោចណាស់ ២/៣ (ពីរភាគបី) នៃសមាជិកគណៈកម្មការប្រតិបត្តិ។

## ជំពូកទី ៥

## វិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬវិសោធនកម្មលក្ខន្តិកៈ

**ប្រការ២៦.- អំពីវិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់**

**សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** អាចប្តូរឈ្មោះ ឬប្តូរសញ្ញាសម្គាល់បាន តាមសំណើសុំរបស់ប្រធានសមាគម ឬតាមសំណូមពរ ២/៣ (ពីរភាគបី) នៃសមាជិកគណៈកម្មការប្រតិបត្តិរបស់សមាគម។ ការអនុម័តលើរាល់ការសម្រេចនៃការប្តូរឈ្មោះ ឬប្តូរសញ្ញាសម្គាល់របស់សមាគម គឺជាសមត្ថកិច្ចរបស់មហាសន្និបាត។

**ប្រការ២៧.- អំពីការធ្វើវិសោធនកម្មលក្ខន្តិកៈ និងសៀវភៅបន្ទុក "អំបិលកំពតកែប"**

លក្ខន្តិកៈ និងសៀវភៅបន្ទុករបស់ **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** អាចធ្វើវិសោធនកម្មបានតាមសំណើសុំរបស់ប្រធានសមាគម ឬតាមសំណូមពរ ២/៣ (ពីរភាគបី) នៃសមាជិកគណៈកម្មការប្រតិបត្តិរបស់សមាគម។ ការអនុម័ត លើរាល់ការសម្រេចនៃការធ្វើវិសោធនកម្មលក្ខន្តិកៈ និងសៀវភៅបន្ទុករបស់ **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** គឺជាសមត្ថកិច្ចរបស់មហាសន្និបាត។

## ជំពូកទី ៦

## ប្រភពធនធាន ទ្រព្យសម្បត្តិ និងការគ្រប់គ្រង

**ប្រការ២៨.- អំពីប្រភពធនធាន ទ្រព្យសម្បត្តិ**

**សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** មានប្រភពមូលនិធិបានមកពី៖

- ភាគទាន ឬវិភាគទាន ឬបរិវិសទានរបស់សមាជិក
- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់សមាគម
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ការបង់ថ្លៃផាកពិន័យលើការក្លែងបន្លំប្រើប្រាស់ឈ្មោះ **"អំបិលកំពតកែប"**
- ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត (ថ្លៃបដិភាគពីការលក់អំបិលកំពតកែប)

**ប្រការ២៩.- អំពីការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ**

រាល់ចំណូលទាំងអស់របស់ **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** ត្រូវគ្រប់គ្រងដោយហេរញ្ញិក របស់សមាគមដោយមានការចុះហត្ថលេខាយល់ព្រមពីប្រធានសមាគម។ ចំណូលជាសាច់ប្រាក់ ឬមូលប្បទានប័ត្រទាំងអស់ ត្រូវបញ្ចូលទៅក្នុងគណនីធនាគារស្របច្បាប់ណាមួយរបស់សមាគមនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៅតាមការសម្រេចរបស់គណៈកម្មការប្រតិបត្តិ។

ថវិកាអាចរក្សាទុកមួយចំនួននៅក្នុងបេឡារបស់ **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** សម្រាប់ប្រើប្រាស់ជាការចាំបាច់ក្នុងសមាគមតាមការកំណត់របស់គណៈកម្មការប្រតិបត្តិ។

រាល់ការដកសាច់ប្រាក់ ឬមូលប្បទានប័ត្រពីធនាគារ ត្រូវមានការចុះហត្ថលេខារបស់ហេរញ្ញិក និងប្រធាន **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** ឬអាចផ្ទេរសិទ្ធិទៅឱ្យរូបវន្តបុគ្គល ដែលជាសមាជិកគណៈកម្មការប្រតិបត្តិតាម ការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីសាមីខ្លួនដែលមានសិទ្ធិ។

## ជំពូកទី ៧
## ការផ្អាកសកម្មភាព ការរំលាយសមាគម ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ

**ប្រការ៣០.- អំពីការផ្អាកសកម្មភាពសមាគម**

មានតែមហាសន្និបាតតែ ១(មួយ)គត់ ដែលអាចសម្រេចក្នុងការផ្អាកសកម្មភាព **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** នេះបាន។ មុនពេលសមាគមត្រូវបានផ្អាកសកម្មភាព មហាសន្និបាតត្រូវរៀបចំបង្កើតគណៈកម្មការមួយដើម្បីគ្រប់គ្រងនូវទ្រព្យសម្បត្តិរបស់សមាគម។

**ប្រការ៣១.- អំពីការរំលាយសមាគម**

មានតែមហាសន្និបាតតែ ១(មួយ)គត់ ដែលអាចសម្រេចក្នុងការរំលាយ **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** នេះបាន។ មុនពេលសមគមត្រូវបានរំលាយមហាសន្និបាតត្រូវរៀបចំបង្កើតគណៈកម្មការមួយដើម្បីជម្រះបញ្ជីរបស់សមាគម។ ការសម្រេចចិត្តក្នុងការរំលាយសមាគម អាចធ្វើទៅបានលុះត្រាតែមានសម្លេងយល់ព្រមពីសមាជិកសកម្មចំនួនចាប់ពី ៨០% ឡើងទៅ។

**ប្រការ៣២.- អំពីចាត់ចែងទ្រព្យសម្បត្តិ**

រាល់ទ្រព្យសម្បត្តិរបស់ **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** ដែលនៅសល់ក្រោយពីជម្រះបំណុលស្របច្បាប់របស់ សមាគមរួចត្រូវប្រគល់ជូនសមាគមជាតិកាកបាទក្រហមកម្ពុជា ឬសមាគមអង្គការដែលមានគោលបំណងប្រហាក់ប្រហែលនឹង **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប**។ សមាជិកនិងបុគ្គលិកសមាគមទាំងអស់ក៏ត្រូវរំសាយផងដែរ នៅពេលដែលសមាគមត្រូវបានរំលាយ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**ប្រការ៣៣.-**

រាល់បទប្បញ្ញត្តិទាំងឡាយណារបស់ **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** ដែលមានខ្លឹមសារផ្ទុយពីលក្ខន្តិកៈនេះនឹងត្រូវទុកជានិរាករណ៍។

**ប្រការ៣៤.-**

**សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** ត្រូវធ្វើសកម្មភាពដោយអនុវត្តឱ្យស្របតាមលក្ខន្តិកៈរបស់ខ្លួន ដូចដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ប្រការ៣៥.-**

លក្ខន្តិកៈរបស់ **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប** មានសុពលភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.....ធន្ទ..១៩.រោច...ខែ....ផល្គុន....ឆ្នាំខាល ពស.២៥៦៦

ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៣

**ជ.គណៈកម្មការប្រតិបត្តិ**

**ប្រធាន**

**ប៊ុន ណារិន**

បានតម្កល់ទុកលក្ខន្តិកៈ
របស់
សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប
ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ តាមប្រកាស
លេខៈ២៤៤៥៥.ប្រ.ក ចុះថ្ងៃទី២០ខែមេសាឆ្នាំ ២០២៣។
រាជធានីភ្នំពេញ. ថ្ងៃទី២០..ខែមេសាឆ្នាំ ២០២៣
នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ
ប្រធាន

ឈឹម ភាព

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# រចនាសម្ព័ន្ធ
## សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រអំបិលកំពត កែប (ស.ផ.អ.ក.ក)

Association of Geographical Indication Kampot-Kep Salt (AGIKS)




ថ្ងៃ....ចន្ទ.១៤.រោច...ខែ...ផល្គុន.....ឆ្នាំខាល ពស.២៥៦៦

ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៣

**ជ.គណៈកម្មការប្រតិបត្តិ**

**ប្រធាន**

**ប៊ុន ណារិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធ

## សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប ( ស.ផ.អ.ក.ក )

Association of Geographical Indication Kampot-Kep Salt (AGIKS)

ក/សញ្ញាសម្គាល់

ខ/ត្រា

ថ្ងៃ.....ចន្ទ..១៨.រោច.....ខែ....ផល្គុន.....ឆ្នាំខាល ពស.២៥៦៦

ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៣

**ជ.គណៈកម្មការប្រតិបត្តិ**

**ប្រធាន**

**ប៊ុន ណារិន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ឧបសម្ព័ន្ធ ស្តីពី សមាសភាព
## សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រអំបិលកំពត កែប (ស.ផ.អ.ក.ក)
Association of Kampot-Kep Salt Producers (AGIKS)

| ក/ទីប្រឹក្សា | | |
|---|---|---|
| ល.រ | ឈ្មោះ | តួនាទី |
| ១ | | |
| ២ | | |
| ៣ | | |

| ខ/គណៈកម្មការប្រតិបត្តិ | | |
|---|---|---|
| ល.រ | ឈ្មោះ | តួនាទី |
| ១ | លោក ប៊ុន ណារិន | ប្រធានសមាគម |
| ២ | លោក ប៊ុន ច័ន្ទតារា | អនុប្រធានសមាគម |
| ៣ | លោកស្រី ប៉ាក ពៅ | អនុប្រធានសមាគម |
| ៤ | លោក អ៊ុយ ហាន់ | សមាជិក |
| ៥ | លោកស្រី សែម សារ៉ន | សមាជិក |
| ៦ | លោក ស៊ីន ណួន | សមាជិក |
| ៧ | លោក ណុប សារ៉េត | សមាជិក |
| ៨ | លោក ស៊ីម សុខុម | សមាជិក |
| ៩ | លោក ចឹក ច័ន្ទរ័ត្ន | សមាជិក |
| ១០ | លោក ឡេហ្ស៊ី សេបាសស្ទៀន | សមាជិក |
| ១១ | លោក ចិក ឧត្តម | សមាជិក |

| គ/សវនករផ្ទៃក្នុង | | |
|---|---|---|
| ល.រ | ឈ្មោះ | តួនាទី |
| ១ | លោក គង់ សុខុទ្ធី | សវនករផ្ទៃក្នុង |
| ២ | លោក សេម វិចិត្រ | សវនករផ្ទៃក្នុង |
| ៣ | លោក កែវ ចាន់ថេត | សវនករផ្ទៃក្នុង |

ថ្ងៃ.....ចន្ទ..១៤.រោច...ខែ.....ផល្គុន...ឆ្នាំខាល ពស.២៥៦៦

ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៣

ជ.គណៈកម្មការប្រតិបត្តិ

ប្រធាន

ប៊ុន ណារិន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធ ស្តីពី សមាសភាព

## សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប (ស.ផ.អ.ក.ក)

Association of Kampot-Kep Salt Producers (AGIKS)

| ក/ទីប្រឹក្សា | | |
|---|---|---|
| ល.រ | ឈ្មោះ | តួនាទី |
| ១ | | |
| ២ | | |
| ៣ | | |
| **ខ/គណៈកម្មការប្រតិបត្តិ** | | |
| ល.រ | ឈ្មោះ | តួនាទី |
| ១ | លោក ប៊ុន ណារិន | ប្រធានសមាគម |
| ២ | លោក ប៊ុន ច័ន្ទតារា | អនុប្រធានសមាគម |
| ៣ | លោកស្រី ប៉ាក ពៅ | អនុប្រធានសមាគម |
| ៤ | លោក អ៊ុយ ហាន់ | សមាជិក |
| ៥ | លោកស្រី សែម សារ៉ន | សមាជិក |
| ៦ | លោក ស៊ីន ណួន | សមាជិក |
| ៧ | លោក ណុប សារ៉េត | សមាជិក |
| ៨ | លោក ស៊ឹម សុខុម | សមាជិក |
| ៩ | លោក ចឹក ច័ន្ទរ័ត្ន | សមាជិក |
| ១០ | លោក ឡេហ្សី សេបាសស្ទៀន | សមាជិក |
| ១១ | លោក ចិក ឧត្តម | សមាជិក |
| **គ/សវនករផ្ទៃក្នុង** | | |
| ល.រ | ឈ្មោះ | តួនាទី |
| ១ | លោក គង់ សុវុទ្ធី | សវនករផ្ទៃក្នុង |
| ២ | លោក សេម វិចិត្រ | សវនករផ្ទៃក្នុង |
| ៣ | លោក កែវ ចាន់ថេត | សវនករផ្ទៃក្នុង |

ថ្ងៃ.....ចន្ទ..១៤.រោច...ខែ.....ផល្គុន...ឆ្នាំខាល ពស.២៥៦៦

ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៣

**ជ.គណៈកម្មការប្រតិបត្តិ**

**ប្រធាន**

**ប៊ុន ណារិន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម**
**នាយកដ្ឋានកម្មសិទ្ធិបញ្ញា**

# ពាក្យស្នើសុំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
# APPLICATION FOR GEOGRAPHICAL INDICATION REGISTRATION

| (សម្រាប់មន្ត្រីប្រើប្រាស់ប៉ុណ្ណោះ) | |
|---|---|
| លេខដាក់ពាក្យ: | |
| កាលបរិច្ឆេទដាក់ពាក្យ: | |
| លេខចុះបញ្ជី: | |
| កាលបរិច្ឆេទចុះបញ្ជី: | |

**ផ្នែកទី១**: **អ្នកស្នើសុំ** ( ម្ចាស់ម៉ាក )

អ្នកស្នើសុំដំបូងត្រូវបំពេញផ្នែកនេះ

**ក- អ្នកស្នើសុំ**

(ក) ឈ្មោះ: **សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប**

ជាអក្សរឡាតាំង: ASSOCIATION OF GEOGRAPHICAL INDICATION KAMPOT-KEP SALT PRODUCERS

(ខ) អាសយដ្ឋាន: ផ្ទះលេខ ០០១ ផ្លូវលំ ភូមិទ្វីខាងត្បូង សង្កាត់អណ្ដូងខ្មែរ ក្រុងកំពត ខេត្តកំពត ប្រទេស កម្ពុជា

ជាអក្សរឡាតាំង: House# 001, Plov Lum, Tvi Khang tboung village, Sangkat Andoung Khmer, Krong Kampot, Kampot province, Cambodia.

លេខទូរសព្ទ : 012 330 070 លេខទូរសារ : ........................ អ៊ីម៉ែល: kamdaff@gmail.com

(គ) សញ្ជាតិ/ប្រទេស: ខ្មែរ

**ខ- ភ្នាក់ងារទំនាក់ទំនងក្នុងប្រទេសកម្ពុជា**

អ្នកដែលទទួលបានសិទ្ធិជាភ្នាក់ងារតំណាងក្នុងប្រទេស

(ក) ឈ្មោះ និងអាសយដ្ឋានទំនាក់ទំនង:

.......................................................................................................

លេខទូរសព្ទ:.......................លេខទូរសារ:........................ អ៊ីម៉ែល: .............................

(ខ) លេខចុះបញ្ជី នៃភ្នាក់ងារក្នុងប្រទេស (នៅពេលអនុវត្ត): ........................

## ផ្នែកទី ២: ព័ត៌មានលម្អិតអំពី ពាក្យស្នើសុំម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

(**សម្គាល់:** គំរូម៉ាកសម្គាល់ភូមិសាស្ត្រទំនិញចំនួន១៥ ត្រូវភ្ជាប់មកជាមួយនឹងពាក្យស្នើសុំនេះ)

| |
|---|
| **អំបិលកំពតកែប**<br>**KAMPOT-KEP SALT** |

(ក) ឈ្មោះទំនិញ និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ: **Kampot-Kep salt**

(ខ) ប្រភេទទំនិញ: Salt, Calcium salts, rock salt, salt flower, and edible salt.

(គ) ចំណាត់ថ្នាក់ នៃទំនិញ: 30

(ឃ) លេខកូដវីយ៉ែន ..........................................................................................................

..........................................................................................................................................

(ង) ការពិពណ៌នា អំពីទំនិញសម្គាល់ភូមិសាស្ត្រ:

**"អំបិលកំពតកែប"** ជាអំបិលដែលកែច្នៃចេញពីទឹកសមុទ្រ និងប្រមូលផលតាមបែបប្រពៃណីដោយដៃ ដែលផ្ទុកទៅដោយសូដ្យូមក្លរ និងសំបូរសារជាតុខនិចសំខាន់ៗ ព្រមទាំងសារជាតុចាំបាច់មួយចំនួនទៀតសម្រាប់ជីវិតមនុស្ស និងសត្វ និងមាន ៣ ប្រភេទដូចខាងក្រោម៖

- **អំបិលគ្រួស៖** ជាប្រភេទអំបិលគ្រួស ដែលផលិតផ្ទាល់ចេញពីស្រែបណ្ដុះ
- **អំបិលម៉ដ្ឋ៖** ជាប្រភេទអំបិល ដែលផលិតចេញពីការយកអំបិលគ្រួសទៅកិន
- **ផ្កាអំបិល៖** ជាប្រភេទអំបិលដែលប្រមូលពីផ្ទៃទឹកខាងលើនៃស្រែបណ្ដុះ

## ផ្នែកទី ៣: តំបន់ភូមិសាស្ត្រទំនិញ

(ក) ការកំណត់តំបន់

ការកំណត់តំបន់ភូមិសាស្ត្រនៃការផលិត និងការវេចខ្ចប់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ **"អំបិលកំពតកែប"** មានខេត្តចំនួន ២ ដូចខាងក្រោម៖

➢ **ខេត្តកំពត៖**

| ឈ្មោះតំបន់ | ឈ្មោះស្រុក/ក្រុង | ឈ្មោះឃុំ/សង្កាត់ |
|---|---|---|
| ១. បឹងរូង១ | ទឹកឈូ | ជុំគ្រៀល |
| | | កណ្ដោល |
| | | កំពង់សំរោង |
| | | ត្រពាំងព្រីង |

| ឈ្មោះតំបន់ | ឈ្មោះស្រុក/ក្រុង | ឈ្មោះឃុំ/សង្កាត់ |
|---|---|---|
| ២. បឹងរូង២ | ទឹកឈូ | ជុំគ្រៀល |
| ៣. សេះស | ទឹកឈូ | កូនសត្វ |
| | | ត្រពាំងសង្កែ |
| ៤. បឹងទូក | បូកគោ | បឹងទូក |
| ៥. ត្រើយកោះ | ក្រុងកំពត | ត្រើយកោះ |
| ៦. កំពង់ត្រាច | កំពង់ត្រាច | ឬស្សីស្រុកខាងលិច |
| | | ឬស្សីស្រុកខាងត្បូង |

- **ខេត្តកែប៖** ស្រុកដំណាក់ចង្អើរ និងក្រុងកែប។

(ខ) ការពិពណ៌នា អំពីចរិតលក្ខណៈពិសេសដោយឡែក នៃតំបន់ដែលបានកំណត់

ចរិកលក្ខណៈពិសេសដោយឡែករបស់ "អំបិលកំពតកែប" មានដូចខាងក្រោម៖

| ល.រ | ប្រភេទអំបិល | ទំហំគ្រាប់ | ពណ៌ | ក្លិន | រសជាតិ | សំណើម |
|---|---|---|---|---|---|---|
| ១ | អំបិលគ្រួស | ចាប់ពី ២-១៥មីលីម៉ែត្រ | ស ឬសស្រអាប់ បន្តិច ដែលមាន ឯកសណ្ឋាន ភាពល្អ | ទឹកសមុទ្រ តិចៗពី ធម្មជាតិ | . ប្រៃពីតិចទៅល្មម<br>. ប្រៃជាប់មាត់បានយូរ | តិចជាង ឬស្មើ ១២% |
| ២ | អំបិលម៉ដ្ឋ | ចាប់ពី ១០០-៧០០មីក្រុង | ស ឬសស្រអាប់ បន្តិច ដែលមាន ឯកសណ្ឋាន ភាពល្អ | ទឹកសមុទ្រ តិចៗពី ធម្មជាតិ | . ប្រៃពីល្មមទៅខ្លាំងលឿន<br>. ប្រៃជាប់មាត់បានយូរ | |
| ៣ | ផ្កាអំបិល | ចាប់ពី ៥០០-២០០០មីក្រុង | ស ឬសស្រអាប់ បន្តិច ដែលមាន ឯកសណ្ឋាន ភាពល្អ | ទឹកសមុទ្រ តិចៗពី ធម្មជាតិ | . ប្រៃពីល្មមទៅខ្លាំងលឿន<br>. ប្រៃជាប់មាត់បានយូរ | |

- សារជាតុបន្ថែមផ្សេងៗ អាចប្រើប្រាស់បានទៅតាមលក្ខខណ្ឌតម្រូវនៃច្បាប់ជាតិ ឬប្រទេសនាំចេញ
- គ្រប់ប្រភេទអំបិលទាំងអស់ មិនត្រូវមានឆ្លងនូវសារជាតុគីមីពុល (ថ្នាំសម្លាប់ស្មៅ ថ្នាំសម្លាប់សត្វល្អិត ថ្នាំកម្ចាត់ជំងឺ និងថ្នាំកម្ចាត់ផ្សិត) និងអ៊ីជ្រូកាប្អូរ

## I- ការពិពណ៌នា អំពីវិធីសាស្ត្រផលិត

### ពិពណ៌នាអំពីវិធី នៃការប្រមូលទំនិញ វត្ថុធាតុដើម និងទំនិញដែលត្រូវបានកែច្នៃ៖

ការផលិត "អំបិលកំពតកែប" ចែកចេញជា ៤ ដំណាកកាលធំៗ ដូចខាងក្រោម៖

- **ដំណាក់កាលទី ១៖** ការរៀបចំស្រែ
- **ដំណាក់កាលទី ២៖** ការក្រុងទឹក

- **ដំណាក់កាលទី ៣៖** ការបញ្ចូល និងហាលទឹក
- **ដំណាក់កាលទី ៤៖** ការកំណត់គុណភាពទឹក និងការចាប់ផ្តើមផលិតអំបិល (ព័ត៌មានលម្អិតនៃការ ផលិត **"អំបិលកំពតកែប"** ដូចមានពិពណ៌នាលម្អិតនៅក្នុងសៀវភៅបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ **"អំបិលកំពតកែប"** ដែលមានភ្ជាប់មកជាមួយ)។




គម្រូររចនាសម្ព័ន្ធស្រែអំបិល

## II- សមាសធាតុ ឬឯកសារបង្ហាញពីទំនាក់ទំនងរវាងប្រភពដើមភូមិសាស្ត្រ និងគុណភាពទំនិញ

(ក) សមាសធាតុដែលបញ្ជាក់អំពីគុណភាព កិត្តិស័ព្ទ និង/ឬ ចរិតលក្ខណៈផ្សេងៗទៀតនៃទំនិញសម្គាល់ភូមិសាស្ត្រ

**ដោយយោងទៅតាមលទ្ធផលនៃការសិក្សាទៅលើ "ប្រវត្តិ និងគុណភាពពិសេសរបស់ "អំបិលកំពតកែប" បានបញ្ជាក់ថា៖**

- ផលិតកម្មអំបិលនៅកម្ពុជាមានប្រវត្តិតាំងពីរាប់ពាន់ឆ្នាំមកហើយ
- មានភស្តុតាង និងឯកសារមួយចំនួនបានបង្ហាញថាអំបិលនៅទឹកដីកម្ពុជា មានតាំងពីសតវត្សទី ៧ មកម្ល៉េះ
- អំបិលដែលផលិតមាន ៣ ប្រភេទ រួមមាន អំបិលគ្រួស អំបិលម៉ដ្ឋ និងផ្កាអំបិល
- អំបិលមានផលិតនៅតំបន់កំពតកែបតាំងពីសម័យអាណានិគមនិយមបារាំងមកម្ល៉េះ (នៅក្នុងកំឡុងឆ្នាំ ១៩៣០-១៩៤០)
- នៅកម្ពុជាក្នុងពេលបច្ចុប្បន្ន មានតែតំបន់កំពត និងកែបប៉ុណ្ណោះដែលមានផលិតអំបិល។
- **"អំបិលកំពតកែប"** មានគុណភាពពិសេស ដែលមានលក្ខណៈផ្សារភ្ជាប់ទៅនឹងតំបន់ភូមិសាស្ត្រ (ប្រភេទដី) ឬ/និង ទេពកោសល្យរបស់អ្នកផលិត ដោយអាស្រ័យទៅតាមប្រភេទអំបិល។

(ខ) ទំនាក់ទំនងរវាងតំបន់ភូមិសាស្ត្រ និងកត្តាធម្មជាតិនៃទំនិញសម្គាល់ភូមិសាស្ត្រ ដូចជា ដី អាកាសធាតុ

- តាមលទ្ធផលវិភាគដីនៃតំបន់ផលិតកម្មទាំង ៧ នៃខេត្តកំពត និងខេត្តកែប បានបង្ហាញយ៉ាងច្បាស់ថា ដីស្រែបណ្ដុះ គឺជាប្រភេទដីល្បាយខ្សាច់។ ដីប្រភេទនេះមានឥទ្ធិពលទៅលើគុណភាពពិសេសរបស់ **"អំបិលកំពតកែប"** ដូចដែលមានរៀបរាប់នៅក្នុងចំណុចទី ៤ នៃសៀវភៅបន្ទុក។
- អាកាសធាតុនៅតំបន់កំពត និងកែប ដែលមានការជាប់ទាក់ទងទៅនឹងសមុទ្រចិនខាងត្បូង បានផ្ដល់នូវបរិយាកាសដ៏ល្អសម្រាប់ការផលិត **"អំបិលកំពតកែប"** ដោយប្រើប្រាស់នៅកំដៅព្រះអាទិត្យ។
- នៅតាមតំបន់ផលិតកម្ម "អំបិលកំពតកែប" មានសំបូរទៅដោយព្រៃដើមកោងកាង ដែលមានលក្ខណៈអំណោយផលដល់គុណភាពទឹកសមុទ្រ ដែលជាវត្ថុធាតុដើមដ៏សំខាន់ប្រើប្រាស់សម្រាប់ផលិតប្រភេទអំបិលគ្រួស និងផ្កាអំបិល។

## III- វិធីសាស្ត្រត្រួតពិនិត្យទំនិញសម្គាល់ភូមិសាស្ត្រ

(ក) វិធីសាស្ត្រត្រួតពិនិត្យទំនិញសម្គាល់ភូមិសាស្ត្រ

សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប បានកំណត់នូវវិធីសាស្ត្រត្រួតពិនិត្យម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ **"អំបិលកំពតកែប"** ចំនួន ៣ ដូចខាងក្រោម៖

- **ស្វ័យត្រួតពិនិត្យ៖** គឺជាការត្រួតពិនិត្យដែលធ្វើឡើងដោយផលិតករខ្លួនឯង។ ផលិតករ ត្រូវយល់ដឹងឱ្យបានច្បាស់អំពីសៀវភៅបន្ទុក **"អំបិលកំពតកែប"** ហើយធ្វើយ៉ាងណាឱ្យប្រាកដថា ការអនុវត្តគឺស្របតាមសៀវភៅបន្ទុក។
- **ត្រួតពិនិត្យផ្ទៃក្នុង៖** គឺជាការត្រួតពិនិត្យដែលធ្វើឡើងដោយ សមាគមអ្នកផលិតម៉ាកសម្គាល់ភូមិសាស្ត្រទំនិញអំបិលកំពត កែប។
- **ត្រួតពិនិត្យពីខាងក្រៅ៖** គឺជាការត្រួតពិនិត្យដែលធ្វើឡើងដោយស្ថាប័នឯករាជ្យដែលបានការទទួលស្គាល់ស្របតាមច្បាប់ស្ដីពី **"ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ"** ក្នុងប្រទេសកម្ពុជា។

(ខ) ឈ្មោះ និងអាសយដ្ឋានរបស់អង្គភាពឯករាជ្យចេញវិញ្ញាបនបត្រពីខាងក្រៅ ..............................
..........................................................................................................................................

លេខទូរសព្ទ:......................លេខទូរសារ:..............អ៊ីម៉ែល:....................................

## IV- ព័ត៌មាន ស្ដីពីស្លាកសញ្ញានៃទំនិញសម្គាល់ភូមិសាស្ត្រ

ការធ្វើស្លាកសញ្ញា **"អំបិលកំពតកែប"** អាចដាក់ឈ្មោះ **"អំបិលកំពតកែប"** ជាភាសាខ្មែរ និងអាចមានភាសាដទៃទៀត។ ចំពោះទំហំរបស់វាអាចធំ ឬបំផុតបើប្រៀបធៀបជាមួយអក្សរដទៃទៀតនៅក្នុងស្លាកសញ្ញា។ ចំពោះពាក្យ **"ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ"** អាចដាក់នៅជិតឈ្មោះ **"អំបិលកំពតកែប"** ជាភាសាតែមួយដូចគ្នានឹង **"អំបិលកំពតកែប"**។

ស្លាកយីហោដែលអាចមើលឃើញរួមមាន៖

- ចំណែកនៃស្លាកសញ្ញាទំនិញសម្គាល់ភូមិសាស្ត្រ **"អំបិលកំពតកែប"**
- ស្លាកសញ្ញាទំនិញសម្គាល់ភូមិសាស្ត្រ **"អំបិលកំពតកែប"**

- អាចដាក់ស្លាកសញ្ញាទំនិញសម្គាល់ភូមិសាស្ត្ររបស់ប្រទេសផ្សេងៗទៀត ឬមួយក្រុមប្រទេសដែល **"អំបិលកំពតកែប"** បានចុះបញ្ជីការពារជាទំនិញសម្គាល់ភូមិសាស្ត្រ ប្រសិនបើមាន។
- ស្លាកសញ្ញាសារជាតុបន្ថែម (អ៊ីយ៉ូត) (ក្នុងករណីមានការដាក់សារជាតុបន្ថែម តាមច្បាប់ជាតិ ឬប្រទេសនាំចេញ)។

ក្នុងករណីមិនមានលេខឡូតិ៍នៅលើសំបកវេចខ្ចប់ ប្រតិបត្តិករអាចដាក់លេខឡូតិ៍ នៅលើស្លាកសញ្ញា **"អំបិលកំពតកែប"** ដើម្បីជាជំនួយសម្រាប់ធ្វើឱ្យប្រាកដ ដល់ការស្វែងរកតឹកតាងនៃផលិតផល។

## V- ឯកសារដែលត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ

(ក) លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សមាគមសម្គាល់ភូមិសាស្ត្រទំនិញៈ (១ច្បាប់)
(ខ) លិខិតចុះបញ្ជីសមាគមសម្គាល់ភូមិសាស្ត្រទំនិញ នៅក្រសួងមហាផ្ទៃៈ (១ច្បាប់)
(គ) សៀវភៅបន្ទុកៈ (១ច្បាប់)
(ឃ) ផែនទី នៃតំបន់ផលិតកម្មៈ (១ច្បាប់)
(ង) ឯកសារបង្ហាញពីប្រព័ន្ធតាមដានតឹកតាងដើម្បីបញ្ជាក់ថាទំនិញ មានប្រភពពីតំបន់ភូមិសាស្ត្រៈ (១ច្បាប់)
(ច) ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស ត្រូវបង្ហាញភស្តុតាងពីកិច្ចការពារនៅក្នុងប្រទេសដើម
(ឆ) ឯកសាររៀបរាប់ពីផែនការត្រួតពិនិត្យៈ (១ច្បាប់)
(ជ) ឯកសារពាក់ព័ន្ធនឹងកាតាឡុកទណ្ឌកម្មៈ (១ច្បាប់)
(ឈ) របាយការណ៍ត្រួតពិនិត្យផ្ទៃក្នុង និងត្រួតពិនិត្យពីខាងក្រៅៈ (១ច្បាប់)
(ញ) បញ្ជីគណនេយ្យផលិតផលៈ (១ច្បាប់)
(ដ) ពាក្យស្នើសុំចូលជាសមាជិកជាសមាជិកសមាគម និងកិច្ចសន្យា : (១ច្បាប់)
(ឋ) ផែនការត្រួតពិនិត្យៈ (១ច្បាប់)
(ឌ) ឯកសារពាក់ព័ន្ធផ្សេងៗទៀត ដែលតម្រូវដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញាៈ (១ច្បាប់) (បើមាន)
(ណ) វិក័យប័ត្រទូទាត់ថ្លៃសេវាកម្មៈ (១ច្បាប់)

## VI- ឯកសារផ្សេងៗទៀត

……………………………………………………………………………………………………………….

……………………………………………………………………………………………………………….

## VII- ហត្ថលេខារបស់អ្នកស្នើសុំ ឬភ្នាក់ងារតំណាង

(ក) ហត្ថលេខាៈ [signature] (Stamp)
(ខ) ឈ្មោះអ្នកចុះហត្ថលេខាៈ ប៉ង សារ៉ែន
(គ) តួនាទីៈ ប្រធានសមាគម
(ឃ) ថ្ងៃ/ខែ/ឆ្នាំៈ ១៩ មេសា ២០២៣